00207925

ឯកសារ D 96/1

**គោរពជូនលោកសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

***សំណុំរឿងស៊ើបអង្កេតលេខ៖ ០០១/១៨-០៧-២០០៧ - អ.វ.ត.ក/ក.ស.ច.ស***

**កម្មវត្ថុ៖** ការដាក់តម្កល់សារណាដោយក្រុមមេធាវីការពារក្ដីរបស់លោក កាំង ហ្កេក អ៊ាវ ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា

លោកសហចៅក្រមស៊ើបអង្កេតជាទីគោរពដ៏ខ្ពង់ខ្ពស់

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានស្ថាពរពីសំណាក់សហព្រះរាជអាជ្ញា នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ យើងខ្ញុំ **ការ សាវុត្ថ** និង **François Roux** សហមេធាវីរបស់លោក **កាំង ហ្កេក អ៊ាវ** ហៅ **ឌុច** សូមផ្ញើរជូនលោកសហចៅក្រម នូវសារណាស្ដីពីកំណត់សម្គាល់ផ្សេងៗរបស់យើងខ្ញុំ។

ក្រុមមេធាវីការពារក្ដីសូមបញ្ជាក់ថា កំណត់សម្គាល់ទាំងនេះមិនដាក់កំហិតអ្វីឡើយចំពោះសិទ្ធិលើកឡើងនូវកំណត់សម្គាល់បន្ថែមគ្រប់បែបយ៉ាង ដែលយើងខ្ញុំយល់ឃើញថាជាការចាំបាច់នៅពេលជំនុំជម្រះ។

សូមលោកសហចៅក្រមស៊ើបអង្កេតមេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨
សម្រាប់សហមេធាវីទាំងពីររូប
មេធាវីម្នាក់ក្នុងចំណោមមេធាវីទាំងពីររូប

លោក **ការ សាវុត្ថ**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 07 / 2008
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / July / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

00207926

ERN/No D96/1

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / July / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត

# អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

| | |
|---|---|
| **សំណុំរឿងលេខ ៖** | ០០១/១៨-០៧-២០០៧-អ.វ.ត.ក./ក.ស.ច.ស. |
| **ដាក់តម្កល់ជូន ៖** | សហចៅក្រមស៊ើបអង្កេត |
| **កាលបរិច្ឆេទនៃឯកសារ ៖** | ២៤ កក្កដា ២០០៨ |
| **ភាគីអ្នកដាក់តម្កល់ ៖** | មេធាវីរបស់លោក កាំង ហ្គេកអ៊ាវ |
| **ភាសាដើម ៖** | ភាសាបារាំង |
| **ប្រភេទឯកសារ ៖** | **សម្ងាត់** |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 07 / 2008
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## សារណាពីសំណាក់ក្រុមមេធាវីការពារក្តី

---

| <u>ដាក់តម្កល់ដោយ</u> ៖ | <u>ដាក់តម្កល់ជូន</u> ៖ |
|---|---|
| **មេធាវីរបស់លោក កាំង ហ្គេកអ៊ាវ** | **សហចៅក្រមស៊ើបអង្កេត** |
| លោក **ការ សាវុត្ថ** | លោក **យូ ប៊ុនឡេង** |
| លោក **François ROUX** | លោក **Marcel LEMONDE** |

ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨

## សារណាពីសំណាក់ក្រុមមេធាវីការពារក្តី

### I. កំណត់សម្គាល់បឋម ៖

1. គោលបំណងនៃការស៊ើបសួរ គឺប្រមែប្រមូលតាមរបៀបជំទាស់ នូវការពន្យល់ពីសំណាក់ជនត្រូវចោទ ទៅលើការចោទប្រកាន់មកលើខ្លួនដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។
2. ប្រសិនបើជនត្រូវចោទយល់ព្រមពន្យល់អំពីគំនិតរបស់ខ្លួននោះ គឺគួរតែរាប់បញ្ចូលការពន្យល់របស់គាត់ទាំងនោះ ហើយផ្តល់ទំនុកចិត្តទៅលើការពន្យល់ទាំងនោះផងដែរ ដរាបណាការពន្យល់ទាំងនោះមិនទាន់មានភស្តុតាងផ្ទុយ។
3. នៅក្នុងស្ថានភាពឥឡូវនេះ នៅខ្វះចំណុចពីរដ៏សំខាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ៖

   - ការណ៍ដែលមានការស៊ើបសួរក្នុងរយៈពេលជាង១០ខែ ដែលជនត្រូវចោទបានសហការយ៉ាងពេញលេញ ហើយនៅក្នុងរយៈពេលនោះមានការសួរចម្លើយចំនួន២១ថ្ងៃ មានការស៊ើបអង្កេតដល់ទីកន្លែងនៅជើងឯក និងនៅទួលស្លែងចំនួន២ថ្ងៃ ដែលសុទ្ធសឹងជាវិធានការស៊ើបអង្កេតដ៏សំខាន់និងដែលមិនបានគ្រោងទុកជាមុនថាអាចធ្វើបាន ហើយព្រមទាំងមានការពិភាក្សាតទល់គ្នាជាមួយសាក្សីនិងជនរងគ្រោះ អស់រយៈពេលពីរថ្ងៃផងដែរ។

   - ការណ៍ដែល ឌុច បានសម្រេចយល់ព្រមទទួលស្គាល់ភាពទទួលខុសត្រូវរបស់ខ្លួន និងបានសម្រេចសហការក្នុងការស្វែងរកឲ្យឃើញការពិត។
4. ទោះបីជាវត្តមានយ៉ាងខ្ជាប់ខ្ជួនរបស់សហព្រះរាជអាជ្ញានៅពេលមានការស៊ើបសួរ និងសំណួរជាច្រើនរបស់ពួកគាត់ ពិតជាវិភាគទានមិនអាចប្រកែកបាននៅក្នុងនីតិវិធីស៊ើបអង្កេតក៏ដោយ ក៏ប៉ុន្តែដីកាសន្និដ្ឋានស្ថាពរគ្មានឆ្លុះបញ្ចាំងអំពីសេចក្តីសន្និដ្ឋានដ៏សមហេតុផលនៃដំណាក់កាលស៊ើបសួរទេ។
5. នៅក្នុងដីកាសន្និដ្ឋានស្ថាពរ គឺជាការងាររបស់សហព្រះរាជអាជ្ញាដែលត្រូវបង្ហាញអំពីអង្គហេតុទាំងអស់ដែលការស៊ើបសួរអាចកំណត់បង្កើតបាន។
6. ក៏ប៉ុន្តែក្រុមមេធាវីការពារក្តីបានសង្កេតឃើញថា នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ សហព្រះរាជអាជ្ញាបានថ្លែងអំពីអង្គហេតុមួយចំនួនដែលមិនត្រូវបានកំណត់នៅក្នុងពេលស៊ើបសួរទេ។

7. *ជាបឋម* ក្រុមមេធាវីការពារក្តីសូមគូសបញ្ជាក់ថា សហព្រះរាជអាជ្ញាចាត់ទុកអង្គហេតុជាច្រើនថាត្រូវបានកំណត់រួចហើយ ទោះជាអង្គហេតុទាំងនោះសម្អាងលើឯកសារ ឬ "សក្ខីកម្ម" ដែលត្រូវបានប្រមែប្រមូលនៅខាងក្រៅពីនីតិវិធីតុលាការ និងមិនត្រូវបានធ្វើការពិភាក្សាតទល់គ្នានៅពេលការស៊ើបសួរក៏ដោយ។
8. ជាឧទាហរណ៍ មានអត្ថបទសរសេរដោយអ្នកសារព័ត៌មានខ្លះឬសក្ខីកម្មជាច្រើនរបស់ "សាក្សី" ដែលDC-Cam បានប្រមែប្រមូល ហើយដែលត្រូវបានលើកឡើងនៅក្នុងកំណត់សម្គាល់នៅផ្នែកខាងក្រោមទំព័រនៃដីកាសន្និដ្ឋានស្ថាពរ។
9. *ទីពីរ* ក្រុមមេធាវីការពារក្តីកត់សម្គាល់ថា ជាច្រើនលើក សហព្រះរាជអាជ្ញាបានយកសេចក្តីថ្លែងការណ៍មួយចំនួនរបស់ឌុចឬរបស់សាក្សីនៅពេលការស៊ើបសួរ មកធ្វើការបកស្រាយឬប្រើប្រាស់ដោយដោយភាន់ច្រឡំឬដោយមិនពេញលេញ។ ជាលទ្ធផល សហព្រះរាជអាជ្ញាបង្ហាញពីអង្គហេតុដែលគាត់អះអាងថាជាអង្គហេតុកំណត់រួចហើយ ទោះបីជាមិនបានកំណត់មែនទែននៅឡើយក៏ដោយ។
10. សូមអានជាឧទាហរណ៍ អំណះអំណាងរបស់សហព្រះរាជអាជ្ញា នៅកថាខ័ណ្ឌ ១៤៩ នៃដីកាសន្និដ្ឋានស្ថាពរដែលថា *"គាត់ទទួលខុសត្រូវដោយផ្ទាល់ចំពោះអ្នកត្រូវបានចាប់ខ្លួនសំខាន់ៗ"* និងកំណត់សម្គាល់លេខ ៨០៩ នៅផ្នែកខាងក្រោមទំព័រ ដែលយោងទៅលើកំណត់ហេតុសាកសួរចម្លើយ ចុះថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០០៧ (D២៩) ជាពិសេសនៅទំព័រ ERN ០០១៥៣៥៧១។ ឯកសារនេះមិនបញ្ជាក់ទាល់តែសោះថា ឌុចបានធ្វើការចាប់ចងដោយផ្ទាល់ខ្លួន។
11. ម្យ៉ាងវិញទៀត ដោយមិនខ្លាចសរសេរផ្ទុយពីគ្នា សហព្រះរាជអាជ្ញាបញ្ជាក់នៅក្នុងកំណត់សម្គាល់លេខ ៨២៦ នៅផ្នែកខាងក្រោមទំព័រថា *"Duch denies that he ever arrested anyone"* (ការបកប្រែក្រៅផ្លូវការ ៖ "ឌុចបដិសេធថាខ្លួនមិនដែលធ្លាប់បានចាប់មនុស្សណាមួយឡើយ")។
12. *ទីបី* ក្រុមមេធាវីការពារក្តីកត់សម្គាល់ថា ជួនកាល សហព្រះរាជអាជ្ញាបានចាត់ទុកថា អង្គហេតុខ្លះត្រូវបានកំណត់ដោយសម្អាងទៅលើសក្ខីកម្មដែលបានប្រមែប្រមូលនៅពេលការស៊ើបសួរ ហើយមិនដែលត្រូវបានបញ្ជាក់បន្ថែម និង/ឬ មិនគួរឲ្យទុកចិត្ត។
13. ជាឧទាហរណ៍ ក្រុមមេធាវីការពារក្តីចាត់ទុកថា ការតទល់គ្នានៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ (D៥៤) អាចបង្ហាញបានថា សាក្សី ប្រាក់ ខាន (Prak Khan) មិនមែនជាសាក្សីមួយដែលគួរឲ្យទុកចិត្តទេ ៖ បើតាមគាត់ គាត់បានមានវត្តមាននៅគ្រប់ទីកន្លែងទាំងអស់ នៃរាល់បទឧក្រិដ្ឋដែលមានការចោទប្រកាន់ ហើយគាត់បានឃើញនិងបានលឺនូវអ្វីៗទាំងអស់។ សក្ខីកម្មនេះគឺគួរឲ្យសង្ស័យមែន ដោយសារតែវាគ្រប់ជ្រុងជ្រុយពេក។ ម្យ៉ាងទៀត វាមិនមែនជាភាពចៃដន្យទេដែល

សក្ខីកម្មនេះមិនបានទទួលការបញ្ជាក់បន្ថែមពីសាក្សីណាម្នាក់ផ្សេងទៀត។ ការបញ្ជាក់បន្ថែមពីសាក្សីដទៃទៀតនេះគង់តែមាន បើសិនជាសក្ខីកម្មនេះពិតជាបង្ហាញពីការពិតមែន។

14. *ទីបួន* សហព្រះរាជអាជ្ញាយោងទៅលើឯកសារខ្លះដើម្បីអះអាងថា អង្គហេតុមួយចំនួនត្រូវបានកំណត់រួចហើយ ទោះបីជាឯកសារទាំងនេះ ជួនកាល បង្ហាញថាគ្មានការពាក់ព័ន្ធទាល់តែសោះដើម្បីផ្តល់ភស្តុតាងអំពីអង្គហេតុខាងដើមនេះក៏ដោយ។

15. សូមអានជាឧទាហរណ៍ ឯកសារដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់នៅផ្នែកខាងក្រោមទំព័រលេខ ៨៥៨ គឺរូបថតមួយដែលចេញមកពី ស.២១ D៦៩-0000៥ ERN P 0000៥២៤៩ ។ បើយោងតាមសហព្រះរាជអាជ្ញា រូបថតនេះអាចកំណត់ថា ឌុច *"ជារឿយៗគាត់បានត្រួតពិនិត្យការសួរចម្លើយ ដោយអង្គុយជាមួយឬចូលជំនួសអ្នកសួរចម្លើយ"* (សូមអានកថាខ័ណ្ឌទ ១៥៥ នៃដីកាសន្និដ្ឋាន)។ រូបថតនេះដែលត្រូវបានបង្ហាញដល់ ឌុច នៅពេលធ្វើការស៊ើបអង្កេតដល់ទីកន្លែងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ នៅទួលស្លែង (សូមអានកំណត់ហេតុនៃការជូនទៅដល់ទីកន្លែង D៤៨-២ កថាខ័ណ្ឌ ៨.១) គ្មានទាក់ទងអ្វីជាមួយនឹងការសួរចម្លើយឡើយ។

16. ឧទាហរណ៍មួយទៀត នៅក្នុងករណីខ្លះ សហព្រះរាជអាជ្ញាផ្តល់សេចក្តីបកប្រែជាភាសាអង់គ្លេសនៃឯកសារមួយចំនួន ដែលសេចក្តីបកប្រែនេះគឺខុសពីឯកសារដើមជាភាសាខ្មែរ។

17. សូមអានជាអាទិ៍ កំណត់សម្គាល់នៅផ្នែកខាងក្រោមទំព័រលេខ ៨៦១ ដែលមានក្នុងកថាខ័ណ្ឌ ១៥៦ នៃដីកាសន្និដ្ឋាន ដែលយោងទៅលើឯកសារមួយដែលមានចំណងជើងថា *"Torture manual" ("សៀវភៅណែនាំពីទារុណកម្ម")* (ERN 0000៧៤៤៥-000៧៥១៣) ទោះបីជា នៅពេលការស៊ើបសួរនិងដោយមានវត្តមានរបស់សហព្រះរាជអាជ្ញាផង មានការកត់ត្រាថា គឺជាការបកប្រែខុសពីចំណងជើងពិតប្រាកដ៖ *"បញ្ជីស្ថិតិនៃការិយាល័យសន្តិសុខ ស.២១ - នយោបាយ ទឹកចិត្តនិងការរៀបចំ"* (សូមអានកំណត់ហេតុ សួរចម្លើយ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ - ឃ៤៦ ទំព័រទី៥នៃឯកសារជាភាសាបារាំង)។

18. ដោយសម្អាងលើកំណត់សម្គាល់ខាងលើទាំងនេះ ក្រុមមេធាវីការពារក្តីចាត់ទុកថា អង្គហេតុជាច្រើនដែលចែងនៅក្នុងដីកាសន្និដ្ឋានស្ពាពរ គឺមិនត្រូវបានកំណត់ទាល់តែសោះ នៅពេលការស៊ើបសួរ។

## <u>II. កំណត់សម្គាល់ពិសេស</u>

19. ម្យ៉ាងទៀត ក្រុមមេធាវីការពារក្តីសូមជម្រាបជូនដំណឹងលោកសហចៅក្រមស៊ើបអង្កេត នូវចំណុច នៃដីកាសន្និដ្ឋានស្ថាពរដែលក្រុមមេធាវីការពារក្តីសូមជំទាស់ និងចំណុចដែលយើងខ្ញុំមានបំណង ទាក់ទាញចំណាប់អារម្មណ៍របស់លោកសហចៅក្រមស៊ើបអង្កេត។

ក) <u>ចំណុចនៃដីកាសន្និដ្ឋានស្ថាពរដែលក្រុមមេធាវីការពារក្តីជំទាស់</u>

20. ដោយផ្ទុយទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានរបស់ខ្លួន ក្រុមមេធាវី ការពារក្តីចាត់ទុកថា ការស៊ើបសួរមិនអាចកំណត់បាននូវអង្គហេតុដូចខាងក្រោមនេះទេ៖

➢ <u>ស.២១ ស្ថិតនៅកំពូលនៅក្នុងឋានានុក្រមនៃមន្ទីរសន្តិសុខ</u>

21. សហព្រះរាជអាជ្ញាអះអាងដោយគ្មានភ័ស្តុតាង នៅកថាខ័ណ្ឌទី ៤៤ ទំព័រទី ១៧ នៃដីកាសន្និដ្ឋាន ស្ថាពរជាភាសាបារាំងថា *"ស.២១ឋិតនៅខ្ពស់ជាងគេក្នុងប្រព័ន្ធឋានានុក្រមនៃមន្ទីរសន្តិសុខនានា"* ។ ក៏ប៉ុន្តែ តាមការពិនិត្យដោយអ្នកជំនាញ Raoul Jennar ដែលបានដាក់តម្កល់ជូន នៅថ្ងៃទី៩ ខែ ឧសភា ឆ្នាំ២០០៨ - D៨២ ទំព័រទី ៧ និង ៨ បានបង្ហាញដោយសម្អាងទៅលើភ័ស្តុតាងពីភាពផ្ទុយ នឹងអង្គហេតុនេះ។ សូមអានជាពិសេស កថាខ័ណ្ឌ ៥ ដែលមានចំណងជើងថា *ឧបករណ៍សន្តិសុខ ៖ សន្តិបាល ៖ "DC-Cam បានរកឃើញមន្ទីរសន្តិសុខចំនួន ១៩៦ នៅលើទឹកដីទាំងមូល។ មន្ទីរ ទាំងនោះចែកចេញជាបួនប្រភេទ ហើយប្រភេទនីមួយៗស្ថិតនៅក្រោមអំណាចរដ្ឋបាលដែលមាន សមត្ថកិច្ច ដោយគ្មានឋានានុក្រមរវាងថ្នាក់នីមួយៗទេ"*។

<u>ការចូលរួម "យ៉ាងសកម្ម" របស់ស.២១ ក្នុងការចាប់ចង</u>

22. កថាខ័ណ្ឌទី៤៤នៃដីកាសន្និដ្ឋានស្ថាពរអះអាងថា *"ស.២១ មានសិទ្ធិអំណាចចាប់ខ្លួន"*។ សូមអាន ផងដែរ កថាខ័ណ្ឌទី៦៤ និង៦៦នៃដីកាសន្និដ្ឋានស្ថាពរ ដែលចាត់ទុកអង្គភាពពិសេស ស.២១ ថាជា *"កងចាប់ខ្លួន"*មួយ។

23. ក៏ប៉ុន្តែ នៅក្នុងឧបសម្ព័ន្ធ II នៃកំណត់ហេតុសួរចម្លើយ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ (D៤៦) ឌុច បានរៀបរាប់យ៉ាងយូរ ដោយឆ្លើយតបទៅនឹងការស្នើសុំពីសំណាក់សហចៅក្រមស៊ើបអង្កេត អំពី តួនាទីរបស់ស.២១ ដែលបញ្ជាក់ច្បាស់លាស់ថា អង្គភាពនេះមិនបានចូលរួម ទាំងក្នុងការសម្រេច ទាំងក្នុងការអនុវត្តការចាប់ខ្លួន។

24. ឌុច មិនបានទទួលការជំទាស់យ៉ាងម៉ឺងម៉ាត់ ពីសំណាក់សហព្រះរាជអាជ្ញា ឬសាក្សីណាមួយទេ ។

25. ដោយហេតុដូច្នេះ ក្រុមមេធាវីការពារក្តីយល់ឃើញថា ការស៊ើបសួរមិនបានបង្ហាញថា ស.២១ មានអំណាច និង មានសិទ្ធិប្រតិបត្តិការចាប់មនុស្សនោះទេ។

26. ឌុច បានថ្លែងថា គាត់មិនក្តាប់បានទាល់តែសោះនូវសេចក្តីសម្រេចចាប់ចងមនុស្ស ហើយក៏មិនក្តាប់បាននូវនយោបាយដែលត្រូវបានរៀបចំឡើង ទាក់ទងនឹងការចាប់ចង និងការប្រហារជីវិត។

27. ជានិច្ចកាល ឌុច បានបដិសេធថា មិនបានធ្វើសេចក្តីសម្រេចលើការចាប់ចង ហើយបានបញ្ជាក់នៅក្នុងអំឡុងពេលការស៊ើបសួរថា សេចក្តីសម្រេចចាប់អ្នកដែលត្រូវបានបញ្ជូនទៅស.២១ គឺថ្នាក់លើសម្រេចម្នាក់ឯងរហូត។

28. សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧ - D១១ ទំព័រទី៧នៃឯកសារជាភាសាបារាំង៖ *"គ្មានរណាប៊ានចាប់មនុស្ស និងបញ្ជូនគេទៅស.២១ ដោយគ្មានសេចក្តីសម្រេចពីបក្សទេ"*។ សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ - D១៦ ទំព័រទី៦នៃឯកសារជាភាសាបារាំង៖ *"សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់លើ"*។ សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ - D៦៣ ទំព័រទី៨នៃឯកសារជាភាសាបារាំង៖ *"នៅទូទាំងប្រទេសសេចក្តីសម្រេចចាប់ចងរបស់សមាជិកបក្ស និងរបស់កម្មាភិបាលមធ្យម (ដោយមិនរាប់បញ្ចូលកម្មាភិបាលថ្នាក់លើ) ត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍នៃភូមិភាគនីមួយៗ។ ការបញ្ជូនទៅស.២១ ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិម"* ។ សូមអានផងដែរ កំណត់ហេតុសួរចម្លើយ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ - D៦៦ ទំព័រទី៦នៃឯកសារជាភាសាបារាំង៖ *"...គ្មានការចាប់ចងណាមួយអាចកើតមាននៅស.២១ ដោយគ្មានការបង្គាប់ដំបូងពី សុន សេន និងក្រោយមកពី នួន ជា"*។

➢ <u>ការចូលរួមផ្ទាល់ខ្លួនរបស់ ឌុច ក្នុងការសួរចម្លើយ និងការប្រព្រឹត្តិអំពើទារុណកម្ម</u>

29. កថាខ័ណ្ឌទី១៥៥ និង១៥៧នៃដីកាសន្និដ្ឋានស្ថាពរ លើកឡើងពីការចូលរួមផ្ទាល់ខ្លួនរបស់ ឌុច នៅក្នុងការសួរចម្លើយ។ ម្យ៉ាងទៀត កថាខ័ណ្ឌទី១៥៨ នៃដីកាសន្និដ្ឋានស្ថាពរ បញ្ជាក់ថា៖ *"ឌុចឯងផ្ទាល់ក៏បានធ្វើបាប និងបានធ្វើទារុណកម្មអ្នកទោសផងដែរ (...)"*។

30. ក្រុមមេធាវីការពារក្តីសូមបញ្ជាក់ថា ឌុច មិនដែលបានបដិសេធថាគាត់មិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តិយ៉ាងអមនុស្សធម៌ និងអំពើទារុណកម្ម ដែលត្រូវបានប្រព្រឹត្តនៅ ស.២១ នោះទេ។

31. ប៉ុន្តែ ឌុច បានប្រាប់ឲ្យដឹងថា *"គាត់បានចូលរួមយ៉ាងខុសពីធម្មតាបំផុត នៅក្នុងការសួរចម្លើយ"* (សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី១១នៃឯកសារជាភាសាបារាំង) ហើយគាត់បានអះអាងជាប្រចាំថា គាត់បានសួរចម្លើយផ្ទាល់ខ្លួនតែចំពោះមនុស្សម្នាក់ទេ គឺ កុយ ធួន ដោយគ្មានប្រើទារុណកម្មទេ។

32. សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ - D៤៧ ទំព័រទី៤នៃឯកសារជាភាសាបារាំង / កំណត់ហេតុសួរចម្លើយ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧ - D១១ ទំព័រទី៣ និង ៧ នៃឯកសារជាភាសាបារាំង / កំណត់ហេតុសួរចម្លើយ ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ - D២០ ទំព័រទី៦ នៃឯកសារជាភាសាបារាំង / កំណត់ហេតុសួរចម្លើយ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ - D៣០ ទំព័រទី៦ និង៧ នៃឯកសារជាភាសាបារាំង / កំណត់ហេតុសួរចម្លើយ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ទំព័រទី៤នៃឯកសារជាភាសាបារាំង / កំណត់ហេតុសួរចម្លើយ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី១១នៃឯកសារជាភាសាបារាំង ។

33. ម្យ៉ាងទៀត នៅក្នុងឱកាសនៃការតទល់គ្នា នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ (D៥៤) ឌុច បានច្រានចោលការចោទប្រកាន់ដ៏ធ្ងន់ធ្ងរមកលើខ្លួន ទាក់ទងនឹងទារុណកម្ម ដោយសាក្សី ប្រាក់ ខាន់ (Prak Khan) (ទំព័រទី៤នៃកំណត់ហេតុសួរចម្លើយ - ឯកសារជាភាសាបារាំង)។

34. ប៉ុន្តែ ឌុច បានអះអាងនៅថ្ងៃដដែលនោះថា នៅពេលដែលគាត់ជាអនុប្រធាន គាត់ធ្លាប់បានទះកំផ្លៀងអ្នកទោសពីរ បី ដៃ (ទំព័រទី៦នៃកំណត់ហេតុសួរចម្លើយ - ឯកសារជាភាសាបារាំង)។

35. គាត់បានអះអាងយ៉ាងនេះម្តងទៀតនៅក្នុងពេលសួរចម្លើយគាត់ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ (D៧៣)៖ *"ពេលដែលខ្ញុំជាអនុប្រធាន ជួនកាល ខ្ញុំបានទះកំផ្លៀង គឺមិនលើសពីនេះទេ។ពេលដែលខ្ញុំធ្វើប្រធាន ខ្ញុំបានសួរចម្លើយផ្ទាល់ខ្លួនតែ កុយ ធួន ទេ ហើយនេះដោយគ្មានអំពើហឹង្សាទេ"* (ទំព័រទី១១នៃ កំណត់ហេតុសួរចម្លើយ - ឯកសារជាភាសាបារាំង)។

36. ការស៊ើបសួរមិនបានបង្ហាញអំពីការចោទប្រកាន់នៃសហព្រះរាជអាជ្ញាមកលើខ្លួន ឌុច ដោយសម្អាងទៅលើភស្តុតាងទេ។

➢ <u>ឌុច ជាអ្នកសម្រេចឲ្យមានការប្រហារជីវិត</u>

37. សហព្រះរាជអាជ្ញាបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនថា *"អ្នកទោសគ្រប់រូបដែលបានមកដល់មន្ទីរស.២១ គឺទុកសម្រាប់ប្រហារជីវិត។គោលនយោបាយគឺថាគ្មានអ្នកទោសណាម្នាក់*

*អាចត្រូវបានគេដោះលែងឡើយ"* (កថាខ័ណ្ឌទី១១៩) ហើយថា *"ឌុចបានដឹងថា អ្នកទោសទាំងអស់នៅមន្ទីរស.២១ត្រូវបានទុកសម្រាប់សម្លាប់"* (កថាខ័ណ្ឌទី១៦០)។

38. ក៏ប៉ុន្តែ ដោយផ្ទុយពីការអះអាងនេះវិញ នៅក្នុងកថាខ័ណ្ឌទី១៦០នៃដីកាសន្និដ្ឋានរបស់ខ្លួន សហព្រះរាជអាជ្ញាលើកឡើងពីសេចក្តីអះអាងរបស់អតីតសមាជិកនៃបុគ្គលិកស.២១មួយចំនួន ដែលបញ្ជាក់ថា៖ *"ឌុចជាអ្នកសម្រេចថានរណាត្រូវស្លាប់"* (កថាខ័ណ្ឌទី១៦០ នៃដីកាសន្និដ្ឋានស្ពាពរ)។

39. ការស៊ើបសួរបានបង្ហាញយ៉ាងច្បាស់លាស់ថា មាគ៌ានយោបាយរបស់បក្ស គឺត្រូវតែប្រហារជីវិតរបស់មនុស្សទាំងឡាយណាដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅស.២១។

40. នេះក៏ជាលទ្ធផលជាក់លាក់នៃ *"សេចក្តីសម្រេចនៃគណៈមជ្ឈិមស្តីពីបញ្ហានានា"* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ (ERN 0000៣១៣៦-0000៣១៤២) (សូមអាន កំណត់ហេតុសួរចម្លើយ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ - D៧២ ទំព័រទី៦ និង៧នៃឯកសារជាភាសាបារាំង)។

41. សូមអានផងដែរកំណត់ហេតុសួរចម្លើយ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧ - D១១ ទំព័រទី៧នៃឯកសារជាភាសាបារាំង៖ *"... ភាពជាដាច់ខាតៈវា កំណត់ដោយមាគ៌ានយោបាយរបស់បក្ស។ មាគ៌ាដែលកំណត់ថាអ្នកណាដែលត្រូវបានបញ្ជូនទៅស.២១ គឺជាអ្នកដែលត្រូវសម្រេចរួចហើយថាត្រូវតែកំទេច"*។ សូមអាន កំណត់ហេតុសួរចម្លើយ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ - D២៩ ទំព័រទី៦នៃឯកសារជាភាសាបារាំង។

42. ដូច្នេះហើយ សេចក្តីសម្រេចប្រហារជីវិតរបស់អ្នកទាំងនោះ ត្រូវបានធ្វើឡើងមុនអ្នកទាំងនោះត្រូវបានបញ្ជូនមកស.២១។

43. ម្យ៉ាងវិញទៀត មានការយោងទៅលើកថាខ័ណ្ឌទី៣៧នៃដីកាសន្និដ្ឋានស្ពាពរដែលចែងថា៖ *"មន្ទីរសន្តិសុខទាំងអស់បំពេញមុខងារដូចៗគ្នា តាមគោលនយោបាយទូទៅរបស់ ប.ក.ក។ ជាផ្នែកមួយនៃគោលនយោបាយទូទៅ មួយនេះ គេបានប្រើប្រាស់ការធ្វើទារុណកម្ម និងការបង្ករបួសស្នាមដើម្បីបង្ខំឱ្យ "សារភាព" ពី "ឧក្រិដ្ឋកម្ម" ដែលបានចោទប្រកាន់។ "ចម្លើយសារភាព" ត្រូវបានប្រើដើម្បីបញ្ជាក់ថា ការចាប់ខ្លួន និងការសម្លាប់ជនរងគ្រោះគឺជាការត្រឹមត្រូវ និងដើម្បីទទួលបានឈ្មោះអ្នកផ្សេងទៀត ដែលក្រោយមកនឹងត្រូវបានចាប់ខ្លួន ធ្វើទារុណកម្មឱ្យបាន "ចម្លើយសារភាព" ហើយបន្ទាប់មកគឺសម្លាប់ចោល។"*

44. ដូច្នេះហើយ ទោះជាបញ្ជីរបស់មនុស្សដែលត្រូវបានបញ្ជូនទៅប្រហារជីវិតនោះត្រូវតែឱ្យ ឌុចមើលក៏ដោយ ក៏នេះមិនមានន័យថា គាត់មានសិទ្ធិសម្រេចទាក់ទងនឹងការប្រហារជីវិតនោះទេ គឺគាត់គ្រាន់តែមានសិទ្ធិបញ្ជាក់បន្ថែមដល់អ្នកដែលនៅក្រោមបង្គាប់របស់គាត់ថា "ការសារភាព" បានចប់ហើយ បើតាមយោបល់របស់ថ្នាក់លើ។

45. ឌុច មិនអាចដោះលែងនរណាបានឡើយ។

46. លទ្ធភាពតែមួយគត់ដែលគាត់មាន គឺពន្យារពេលប្រហារជីវិតរបស់អ្នកទោស ដើម្បីឱ្យពួកគេអាចធ្វើការឱ្យស.២១ ដូចដែលបានចែងនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញានោះឯង (កថាខ័ណ្ឌទី១៦០)។

➢ <u>ឌុច ដឹងពីអ្វីដែលកើតឡើងនៅថ្នាក់ជាតិ</u>

47. ការដឹងនេះ គឺពិតជាមានកំរិតតិចជាងអ្វីដែលសហព្រះរាជអាជ្ញាបានចែង នៅក្នុងកថាខ័ណ្ឌ ទី១៣២នៃដីកាសន្និដ្ឋានស្ថាពរ៖ *"ឌុចក៏បានដឹងយ៉ាងទូលំទូលាយអំពីឧក្រិដ្ឋកម្មនានាដែលបាននឹងកំពុងប្រព្រឹត្តនៅទូទាំងប្រទេស រួមទាំងការជម្លៀសដោយបង្ខំ ការធ្វើពលកម្មដោយបង្ខំ ប្រព្រឹត្តកម្មអមនុស្សធម៌ ការធ្វើទារុណកម្ម និងការប្រហារ ជីវិតនៅគ្រប់ភូមិភាគ និងរដ្ឋបាលគ្រប់ជាន់ថ្នាក់"*។

48. ប៉ុន្តែ ការស៊ើបសួរបានឱ្យដឹងថា ឌុច មិនបានដឹងទេអំពីវិសាលភាពនៃប្រព័ន្ធឧក្រិដ្ឋកម្ម ដែលនៅក្នុងនោះមានដំណើរការរបស់ស.២១។

49. គាត់ក៏បានអះអាងនៅក្នុងពេលសួរចម្លើយ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ (D៧២ ទំព័រទី៦នៃឯកសារជាភាសាបារាំង)៖ *"នេះគឺនយោបាយសម្ងាត់មួយ។ ម្នាក់ៗ ដឹងតែពីការងារភារកិច្ចរបស់ខ្លួនប៉ុណ្ណោះ។ ហើយ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំ មិនដឹងពីការងារអ្នកដទៃនោះទេ។ ចេញពីចំនុចទាំងអស់នេះ គេមិនអាចសន្និដ្ឋានបានថារបបនេះ ជារបបឧក្រិដ្ឋ ដោយគ្រាន់តែដឹងថា ឧក្រិដ្ឋកម្មនេះ ត្រូវបានប្រព្រឹត្តនៅស២១ប៉ុណ្ណោះនោះទេ។"*

50. សូមអានផងដែរ *"សេចក្តីថ្លែងការនៃបក្សកុម្មុយនិស្តកម្ពុជា ចំពោះបក្សពលករកុម្មុយនិស្តនៃប្រទេសដាន់ម៉ាក (Danemark) ដោយ នួន ជា"* ដែលចែងថា៖ *"ការងារលាក់ការណ៍សំខាន់ណាស់នៅក្នុងអ្វីៗដែលយើងធ្វើ"* (ERN០០០០១៧៨) (សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ - D៧២ ទំព័រទី៨ និង៩នៃឯកសារជាភាសាបារាំង)។

51. កាលពីមុន ឌុច ធ្លាប់បានបញ្ជាក់ថា៖ *"...ខ្ញុំ នៅតែនិយាយថា ខ្ញុំ មិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងប្រធានអង្គភាព មិនថាស៊ូម៉េត ឬ អ្នកដទៃនោះទេ។វា ជាវិន័យដែលមិនអាចបំពានបាន"* (សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ - D៦៨ ទំព័រទី៧នៃឯកសារជាភាសាបារាំង)។

52. ម្យ៉ាងទៀត សហព្រះរាជអាជ្ញាបានសរសេរនៅកថាខ័ណ្ឌទី៦៤នៃដីកាសន្និដ្ឋានរបស់គាត់ថា៖ *"(...)កងការពារ[នៅស.២១]ទាំងនោះ ពុំត្រូវបានអនុញ្ញាតឱ្យនិយាយរកគ្នាទេ ដូច្នេះជាទូទៅបុគ្គលិកម្នាក់ៗមិនបានដឹងពីរបៀបធ្វើការរបស់កងដទៃទៀតទេ។"*

53. ប្រសិនបើភាពដាច់ពីគ្នាដូច្នេះ ដែលជាគោលការណ៍មូលដ្ឋាននៃរបបនោះ មាននៅស.២១មែនដូច្នេះហើយការដែលភាពដាច់ពីគ្នានេះក៏មាននៅថ្នាក់ជាតិផងដែរ តើអាចប្រកែកយ៉ាងម៉េចបាន ?

ខ) <u>ចំណុចដែលយើងខ្ញុំមានបំណងចង់ទាក់ទាញចំណាប់អារម្មណ៍របស់សហចៅក្រមស៊ើបអង្កេត</u>

54. ក្រុមមេធាវីការពារក្តីសូមទាក់ទាញចំណាប់អារម្មណ៍របស់ចៅក្រមទៅលើចំណុចមួយចំនួន ដែលសហព្រះរាជអាជ្ញាមិនបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានស្ពាពររបស់ខ្លួនទេ។

➢ <u>បរិការណ៍មួយដ៏គួរឱ្យភ័យរន្ធត់</u>

55. សូមអានកថាខ័ណ្ឌទី១០២នៃដីកាសន្និដ្ឋានស្ពាពរ៖ *"មានបរិយាកាសនៅមន្ទីរ ស.២១ ពោរពេញដោយការភ័យខ្លាច។ (...) សូម្បីតែបុគ្គលិកបម្រើការនៅមន្ទីរ ស.២១ ក៏ទទួលរងនូវបរិយាកាសភ័យខ្លាចនេះដែរ ហើយជួនកាលក៏ធ្វើអត្តឃាតខ្លួនឯងជាជាងប្រឈមមុខទៅនឹងការដាក់ក្នុងមន្ទីរឃុំឃាំងនៅមន្ទីរ ស.២១ នេះ"*

56. ឌុច និងអ្នកក្រោមបង្គាប់របស់គាត់ មានការភ័យរន្ធត់រហូត។ ពួកគេខ្លាច "អង្គការ" ហើយខ្លាចថ្នាក់ដែលស្ថិតនៅខាងលើស.២១ផ្ទាល់។

57. ពួកគេខ្លាចចំពោះអាយុជីវិតរបស់ខ្លួន និងអាយុជីវិតគ្រួសាររបស់ពួកគេ។

58. ការភ័យរន្ធត់នេះកាន់តែខ្លាំងឡើងៗ ពីព្រោះពួកគេគឺជាសាក្សីផ្ទាល់នៃការកម្ចាត់ ដែលបានកើតឡើងយ៉ាងឆាប់រហ័សនៅក្នុងបក្ស។

59. ឌុច និងកូនចៅរបស់គាត់ភ័យខ្លាំងណាស់ ជាពិសេសដោយសារការដែលមិនអាចគ្រោងទុកជាមុននូវសេចក្តីសម្រេចរបស់ថ្នាក់លើទាក់ទងនឹងមនុស្សដែលត្រូវចាប់។ ពួកគេដឹងថា វេនរបស់ពួកគេអាចមកដល់គ្រប់ពេលវេលា។

60. តើយើងអាចបំភ្លេចយ៉ាងដូចម្តេចបានបើ ជនរងគ្រោះនៅស.២១ស្ទើរតែទាំងអស់គឺជាអតីតកម្មាភិបាលរបស់របប ដែលពួកគេក៏ជាអ្នកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋជាច្រើន មុននឹងមកដល់ស.២១ ហើយនៅក្នុងចំណោមពួកគេ ក៏មានអតីតមេរបស់ ឌុច ផ្ទាល់ផងដែរ។ អំពីបញ្ហានេះ

សូមអានកថាខ័ណ្ឌទី៨១នៃដីកាសន្និដ្ឋានស្ថាពរ៖ *"...ច្រើនជាងបន្តិចពី ៧៨% នៃអ្នកទោសមន្ទីរ ស.២១ គឺមកពីមន្ទីររបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬក៏មកពីអង្គភាពយោធារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។"*

61. សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ - D៦៨ ទំព័រទី៧នៃឯកសារជាភាសាបារាំង។

62. សូមអានផងដែរ កំណត់ហេតុសួរចម្លើយ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី១២ នៃឯកសារជាភាសាបារាំង ដែលនៅក្នុងឯកសារនោះ ឌុច បញ្ជាក់ថា គាត់ *"បានក្លាយខ្លួនជាតួអង្គ និងក៏ជាចំណាប់ខ្មាំងរបស់របបនោះផងដែរ"* ហើយលើកឡើងអំពីការដែលគាត់ភ័យរន្ធត់នៅក្រោយការចាប់មនុស្សបន្តៗគ្នានៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៧។ ពេលនោះ គាត់បានយល់ឃើញថា *"មនុស្សដែលបំរើប្រជាជនអាចត្រូវបានចាប់ខ្លួនក្នុងនាមជាជនក្បត់បក្ស"* ឌុច បន្ថែមថា៖ *"ខ្ញុំមិនមានលទ្ធភាពទប់ស្កាត់វាទេ ហើយ ខ្ញុំ គិតថាតើពេលណាដល់វេនខ្ញុំ។"*

63. សូមអានផងដែរកំណត់ហេតុសួរចម្លើយ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ - D៧២ ទំព័រទី៥ នៃឯកសារជាភាសាបារាំង៖ *"ជាពិសេស ខ្ញុំ មានការរំជួលចិត្តជាខ្លាំង ដោយការចាប់ខ្លួនជាឈុតនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៧ ក្នុងចំណោមកម្មាភិបាលដែលមកពីភូមិភាគឧត្តរ ពីព្រោះ ខ្ញុំមានមនោសញ្ចេតនាចំពោះពួកគេ។ ខ្ញុំ មានការតក់ស្លុតខ្លាំងណាស់ ហើយ បន្ទាប់ពីការចាប់ខ្លួន ង៉ែតយូ ហៅ ហុង នៅថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៧៨ និង វ័នវ៉េត នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ១៩៧៨ ខ្ញុំមានការព្រួយបារម្ភចំពោះអាយុជីវិតខ្ញុំ។"*

➢ <u>ការដែល ឌុច គ្មានលទ្ធភាពដកខ្លួនពីការងាររបស់ខ្លួន</u>

64. នៅពេលការស៊ើបសួរ ឌុច បានបញ្ជាក់ជាច្រើនដងថា គាត់ស្អប់ការងាររបស់គាត់ ហើយគាត់បានសុំមិនធ្វើការងារនេះទេ ប៉ុន្តែការស្នើសុំរបស់គាត់ត្រូវបានបដិសេធ។

65. គឺជាការគួរឱ្យសោកស្តាយណាស់ដែលសហព្រះរាជអាជ្ញាមិនបានលើកឡើងចំណុចនេះ សូម្បីតែមួយម៉ាត់ នៅក្នុងដីកាសន្និដ្ឋានរបស់ខ្លួន។

66. សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី១២ ដែលនៅក្នុងឯកសារនោះ ឌុច សង្ខេបពីបញ្ហាដែលគាត់មិនអាចគេចផុតពីមុខងាររបស់គាត់ ទោះបីជាគាត់បានសុំក៏ដោយ។

67. ក៏ដូចគ្នាដែរ ឌុច បានបញ្ជាក់ថា គ្មានអ្នកក្រោមបង្គាប់គាត់ណាម្នាក់ដែលបានធ្វើការដោយស្ម័គចិត្តនោះទេ។ សូមអានកំណត់ហេតុសួរចម្លើយ ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ D២០ និង ចំណារជា

ហាយលេខហត្ថលេខារបស់ ឌុច ដែលភ្ជាប់ជាមួយឯកសារនោះ នៅទំព័រទី១០៖ *"ពួកគេត្រូវបានចាត់តាំងដោយ បកក (...)។ គ្មាននរណាម្នាក់ស្ម័គចិត្តនោះទេ"*។

68. ម្យ៉ាងទៀត ឌុច ក៏បានបញ្ជាក់នៅក្នុងចំណារនោះថា *"គ្រប់គ្នាមានភាពអាម៉ាស់ដ៏ធំអនេកមិនអាចរស់បាន"* ចំពោះ *"ភារកិច្ច"* ដែលត្រូវបំពេញ។

69. ឌុច ក៏ដូចជាអ្នកក្រោមបង្គាប់របស់គាត់ដែរ បានធ្វើការងារនេះ ពីព្រោះពួកគេគ្មានលទ្ធភាពបដិសេធមិនធ្វើ។
បើបានបដិសេធបានមែន គឺស្មើនឹងការរិះគន់របប ដែលការរិះគន់យ៉ាងនេះត្រូវបានហាមឃាត់ទាំងស្រុង។

➢ <u>ភាពគ្មានលទ្ធភាពគេចខ្លួនរបស់ ឌុច</u>

70. ឌុចចាត់ទុកថា គាត់មិនមានលទ្ធភាពអាចនឹងគេចខ្លួនបានទេ។

71. គាត់ស្ថិតនៅក្រោមការឃ្លាំមើលយ៉ាងហ្មត់ចត់របស់ថ្នាក់លើរបស់គាត់ (សុន សេន ហើយបន្ទាប់មក នួន ជា) ដែល ឌុច មានទំនាក់ទំនងជារឿយៗជាមួយពួកគេ ហើយគាត់ក៏មានការឃ្លាំមើលពីសំណាក់ ប៉ង់ និង លឹន ផងដែរ។

72. ម្យ៉ាងទៀត ការឃ្លាំមើលនេះក៏នៅតែបន្តធ្វើក្រោយឆ្នាំ១៩៧៩។

73. សូមអានកំណត់ហេតុសួរចម្លើយ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ - D៦៧ ទំព័រទី៥ និង៦នៃឯកសារជាភាសាបារាំង និងថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ - D៧២ ទំព័រទី១០ និង១១នៃឯកសារជាភាសាបារាំង។

74. ម្យ៉ាងទៀត ឌុចបានបញ្ជាក់ថា ពេលនោះគាត់មិនអាចធ្វើដំណើរដោយសេរីនៅខាងក្រៅក្រុងភ្នំពេញបានទេ។ គាត់មានតែលិខិតដើរផ្លូវមួយ ដែលអនុញ្ញាតឲ្យគាត់ធ្វើដំណើរបានតែនៅក្នុងក្រុងភ្នំពេញប៉ុណ្ណោះ។

75. ដោយឡែក ឌុច បានបញ្ជាក់ថា គាត់មិនដែលបានឃើញនរណាម្នាក់ចាកចេញពីភ្នំពេញទេ សូម្បីតែ វន វ៉េត ក៏មិនបានឃើញដែរ (សូមអានកំណត់ហេតុសួរចម្លើយ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ - D៦៧ ទំព័រទី៥និង៦នៃឯកសារជាភាសាបារាំង) ហើយគាត់បញ្ជាក់ទៀតថា ការគេចខ្លួនគឺមានន័យស្មើនឹងការស្លាប់ សម្រាប់គាត់...ព្រមទាំងសម្រាប់ក្រុមគ្រួសាររបស់គាត់ផងដែរ។

76. ក្រុមមេធាវីការពារក្តីសង្កេតឃើញនូវអ្វីដូចដែល ឌុច បានអះអាង៖ *"សូម្បីតែមនុស្សដែលសំខាន់ជាង [គាត់] ដូចជា វនវ៉េត Vor Vet សោភឹម Sao Phim ឬ យ៉ា Ya ក៏មិនអាចគេចខ្លួនបាន*

*ដែរ។"* (សូមអានកំណត់ហេតុសួរចម្លើយ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី១២នៃឯកសារជាភាសាបារាំង)។

77. នៅទីបញ្ចប់ ឌុច ក៏ស្ថិតនៅក្រោមការឃ្លាំមើលដ៏ម៉ត់ចត់របស់អ្នកក្រោមបង្គាប់របស់គាត់ផងដែរ។

78. សូមអានកំណត់ហេតុសួរចម្លើយ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ - D៧១ ទំព័រទី៦នៃឯកសារជាភាសាបារាំង៖ *"ម្នាក់ៗ ដោយភ័យខ្លាចពីអាយុជីវិតផ្ទាល់ខ្លួន ត្រួតពិនិត្យតាមដានគ្នាទៅវិញទៅមក។"*

➢ <u>ការងារសំខាន់បំផុតរបស់ ឌុច ៖ "ចម្លើយសារភាព"</u>

79. ដោយសហព្រះរាជអាជ្ញាមិនអាចផ្តល់ការនិយាយជំទាស់ ឌុច បានថ្លែងជាច្រើនលើកច្រើនសារថា គាត់បានប្រើពេលវេលាភាគច្រើនរបស់គាត់ ដើម្បីការងារអាន និងការងារធ្វើចំណារលើចម្លើយសារភាព។

80. នៅក្នុងដីកាសន្និដ្ឋានស្ពាពររបស់ខ្លួន សហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ បានលើកឡើងជាច្រើនលើកថា៖ *"លោក កាំង ហ្គេក អ៊ាវ បានអាន វិភាគ ចារសេចក្តី និងសង្ខេបយ៉ាងល្អិតល្អន់ លើចម្លើយសារភាពភាគច្រើន សម្រាប់ថ្នាក់លើរបស់គាត់"* (សូមអានកថាខ័ណ្ឌទី១៤៣ និងកថាខ័ណ្ឌទី៦៨/១១១/១៥៩ នៃដីកាសន្និដ្ឋានស្ពាពរ) ហើយថា លោក កាំង ហ្គេក អ៊ាវ *"មានសិទ្ធិអំណាចផ្តាច់មុខក្នុងការអាន និងចារ លើចម្លើយសារភាពទាំងនោះ ទៅមេដឹកនាំជាន់ខ្ពស់ ដែលគាត់បានធ្វើជារៀងរាល់ថ្ងៃ"* (កថាខ័ណ្ឌទី១៥៩នៃដីកាសន្និដ្ឋានស្ពាពរ)។

81. ម្យ៉ាងទៀត សហព្រះរាជអាជ្ញាក៏បានលើកឡើងនៅក្នុងកថាខ័ណ្ឌទី៨០នៃដីកាសន្និដ្ឋានស្ពាពរថា មានមនុស្សចំនួនជាង ១២ ៣៨០ នាក់ ត្រូវបានដាក់គុកនៅស.២១ ដែលតួលេខនេះអាចបំភ្លឺអំពីចំនួនចម្លើយសារភាពដែលត្រូវបានប្រគល់ឲ្យ ឌុច ហើយដែលគាត់ត្រូវធ្វើការអត្ថាធិប្បាយនោះឯង។

82. ឌុច ពិតជាបានបញ្ជាក់នៅក្នុងការសាកសួរចម្លើយរបស់ខ្លួនថា *"អត្ថន័យខ្លឹមសារនៃចម្លើយសារភាព គឺជាការងារសំខាន់នៅស២១"* (កំណត់ហេតុសួរចម្លើយ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ - D៦៦ ទំព័រទី៧នៃឯកសារជាភាសាបារាំង) ហើយការងាររបស់ខ្លួនផ្ទាល់ *"ផ្តោតជាសំខាន់លើការធ្វើរបាយការណ៍លើចម្លើយសារភាព និង ធ្វើចំណារលើចម្លើយសារភាពទាំងនោះ"* (កំណត់ហេតុសួរចម្លើយ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី៦នៃឯកសារជាភាសាបារាំង)។

83. ឌុច ក៏បានបញ្ជាក់នៅក្នុងពេលសួរចម្លើយចុងក្រោយរបស់ខ្លួនថា គាត់ប៉ាន់ស្មានថាបានអានជាមធ្យម *"២០០ ទំព័រក្នុងមួយថ្ងៃ"* (កំណត់ហេតុសួរចម្លើយ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី៧នៃឯកសារជាភាសាបារាំង)។

84. ក្រៅពីរវល់ក្នុងការងារប្រចាំថ្ងៃនេះ ឌុច ក៏មានទំនាក់ទំនងជារឿយៗជាមួយថ្នាក់លើ ដែលគាត់ត្រូវសរសេររបាយការណ៍ឱ្យពួកគេ ហើយដែលគាត់ត្រូវទទួលការបង្គាប់បញ្ជាពីពួកគេផងដែរ។

85. ដូច្នេះ ក្រុមមេធាវីការពារក្តីចាត់ទុកថា សកម្មភាពរបស់ ឌុច ទាំងអស់នេះ ធ្វើឱ្យគាត់មានពេលវេលាតិចតួចសម្រាប់ធ្វើការគ្រប់គ្រងប្រចាំថ្ងៃទៅលើស.២១ ដែលសហព្រះរាជអាជ្ញាទទួលស្គាល់នៅក្នុងដីកាសន្និដ្ឋានរបស់ខ្លួនថា នៅគ្រប់មន្ទីរសន្តិសុខទូទាំងប្រទេស ការគ្រប់គ្រងនេះត្រូវបានផ្ទេរសិទ្ធិឱ្យអនុប្រធាន (កថាខ័ណ្ឌទី៦០)។ ហើយនៅក្នុងករណីយើងនេះ គឺ ហ៊័រ (Hor) (កថាខ័ណ្ឌទី៦១)។

86. ដោយសម្អាងទៅលើភ័ស្តុតាង ការស៊ើបសួរមិនបានបង្ហាញទេថា ឌុច បានចូលរួមដោយផ្ទាល់ក្នុងការគ្រប់គ្រងប្រចាំថ្ងៃទៅលើស.២១ ថា ឌុច បានពិនិត្យទីកន្លែងឃុំឃាំងយ៉ាងទៀងទាត់ និងថា ឌុច បានសួរចម្លើយអ្នកទោសដោយផ្ទាល់ខ្លួន (សូមអាននៅខាងលើ)។

➢ <u>ឌុច បានទទួលស្គាល់ពីភាពទទួលខុសត្រូវរបស់ខ្លួន</u>

87. ក្រុមមេធាវីការពារក្តីសូមរំលឹកថា ឌុច បានទទួលស្គាល់ទាំងស្រុងចំពោះភាពទទួលខុសត្រូវរបស់ខ្លួនដែលទាក់ទងនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅស.២១ ហើយគាត់ក៏បានសហការនៅគ្រប់ដំណាក់កាលនៃការស៊ើបសួរ ទាំងនៅក្នុងពេលសាកសួរចម្លើយ ទាំងនៅក្នុងការអត្ថាធិប្បាយជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងឯកសារយ៉ាងច្រើនដែលត្រូវបានប្រគល់ឱ្យគាត់ដោយចៅក្រមនិងសហព្រះរាជអាជ្ញា ទាំងនៅក្នុងឱកាសនៃការស៊ើបអង្កេតដល់ទីកន្លែង និងនៅពេលតទល់គ្នាជាច្រើនលើក ។ តាំងពីដំបូងរហូតមក គាត់បានច្រានចោលនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួន...

88. គាត់ក៏បានយល់ព្រមឱ្យមានការធ្វើកោសលវិច័យខាងផ្លូវចិត្តមួយ ដែលបានផ្តល់សេចក្តីបំភ្លឺដ៏មានសារៈសំខាន់ចំពោះការស៊ើបសួរ ប៉ុន្តែសហព្រះរាជអាជ្ញាបែរជាមិនបានលើកឡើងមួយម៉ាត់សោះទាក់ទងនឹងកោសលវិច័យនេះ។

89. នៅទីបញ្ចប់ ឌុច បានសម្តែងនូវវិប្បដិសារីដ៏ស្មោះត្រង់ និងបានសុំអភ័យទោសពីសំណាក់ជនរងគ្រោះ ក្នុងឱកាសនៃការស៊ើបអង្កេតដល់ទីកន្លែង និង នៅក្នុងសវនាការចុងក្រោយ។ សូមអានកំណត់ហេតុស៊ើបអង្កេតដល់ទីកន្លែង ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ - D៤៨ (ឧបសម្ព័ន្ធ ២)

ជាភាសាបារាំង និងកំណត់ហេតុសួរចម្លើយ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ - D៧៣ ទំព័រទី១២៖ *"ជាលើកចុងក្រោយ ខ្ញុំ សុំនិយាយថាខ្ញុំទទួលខុសត្រូវចំពោះអ្វីដែលកើតឡើងនៅស២១។ ខ្ញុំ មានវិប្បដិសារីយ៉ាងជ្រាលជ្រៅ។ ខ្ញុំ នឹងអធិដ្ឋានជាមួយគ្រូរបស់ខ្ញុំ។ ខ្ញុំ សុំការអភ័យទោសពីពួកគេ ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេ ក៏ដូចជាប្រជាជនទាំងមូលផងដែរ។ បក្សនេះ បានបំផ្លាញប្រជាជន។ ខ្ញុំ ជាសមាជិករបស់បក្សនេះ ហើយខ្ញុំសុំទោសប្រជាជនរបស់ខ្ញុំ"*.. វាមានសារៈសំខាន់ណាស់ដែលជនរងគ្រោះចំនួនពីររូបក្នុងចំណោមជនរងគ្រោះដែលមានវត្តមាន បានថ្លែងទៅកាន់សហចៅក្រមស៊ើបអង្កេតថា ៖ "នេះគឺជាពាក្យដែលខ្ញុំទន្ទឹងរង់ចាំអស់រយៈពេលសាមសិបឆ្នាំមកហើយ ហើយខ្ញុំមានសេចក្ដីពេញចិត្តចំពោះពាក្យទាំងនេះ"។

90. ទាក់ទងនឹងចំណុចនេះដែរ សហព្រះរាជអាជ្ញាមិនបានលើកឡើងសូម្បីតែមួយម៉ាត់ ទោះបីជាបុព្វកថានៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញរំលឹកថា "មហាសន្និបាត [នៃអង្គការសហប្រជាជាតិ] បានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ(...)។

**ក្រោមការរក្សាសិទ្ធិគ្រប់យ៉ាង**

| | | | |
|---|---|---|---|
| សម្រាប់សហមេធាវីទាំងពីររូប មេធាវីម្នាក់ក្នុងចំណោមមេធាវីទាំងពីររូប<br>១៤-០៧-២០០៨ | ការ សាវុត្ថ | ភ្នំពេញ | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |